ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យា QR Code "ឈប់ស្កាត់កូវីដ-១៩ (Stop Covid-19)"

ផ្អែកលើសភាពការណ៍នៃការឆ្លងរីករាលដាលក្នុងសហគមន៍ជាបន្តបន្ទាប់ ជាពិសេសព្រឹត្តិការណ៍ "សហគមន៍ ២០កុម្ភៈ ឆ្នាំ២០២១" ដូចដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានជំរាបជូនដល់សាធារណៈជន គណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមជម្រាបជូននូវវិធានការណ៍បន្ថែម ដើម្បីបង្កើនប្រសិទ្ធភាព និងល្បឿនក្នុងការបង្ការ និងទប់ស្កាត់ហានិភ័យនៃការរីករាលដាលជំងឺកូវីដ-១៩ ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានរៀបចំនូវ**ប្រព័ន្ធ QR Code "ទប់ស្កាត់កូវីដ (Stop Covid)"** ដែលសាធារណជនចាំបាច់ត្រូវស្កេន QR Code នៅពេលធ្វើដំណើរចេញ-ចូលទីតាំង សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន កន្លែងកម្សាន្ត អគារស្នាក់នៅរួម (ខុនដូ) ក្រុមហ៊ុន រោងចក្រ សហគ្រាសជាដើម ដែលមានមនុស្សចេញ-ចូលច្រើន។ ប្រព័ន្ធនេះ និងកត់ត្រាទុកទីតាំងរបស់បុគ្គលដែលបានចេញ-ចូល (ជាប្រព័ន្ធដែលមិនមានការតាមដានឯកជនភាពរបស់បុគ្គល) និង ផ្តល់ភាពងាយស្រួលក្នុងការតាមស្វែងរកអ្នកដែលជាប់ពាក់ព័ន្ធឬប៉ះពាល់ ប្រសិនបើទីតាំងនោះ មានរកឃើញករណីវិជ្ជមានវីរុសកូវីដ-១៩។

គណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមណែនាំដល់ម្ចាស់អាជីវកម្ម ម្ចាស់ភោជនីយដ្ឋាន និងម្ចាស់ទីតាំងដែលបានរៀបរាប់ខាងលើដែលមានមនុស្សជួបជុំច្រើន ឱ្យប្រើប្រាស់**ប្រព័ន្ធQR Code "ទប់ស្កាត់កូវីដ-១៩ (Stop Covid-19)"** នេះ ដើម្បីទទួលបាន QR Code យកមកប្រើប្រាស់ សូមចូលទៅកាន់ គេហទំព័រ **stopcovid.gov.kh** រួចចុចលើពាក្យ "ស្នើសុំ QR Code"។ បន្ទាប់មក សូមបំពេញព័ត៌មាន រួចចុចលើ "ស្នើសុំ QR Code" និងចុចលើ "Download" ដើម្បីទទួលបាន QR Code មួយសន្លឹក យកទៅព្រីន និងបិទនៅពីមុខទីកន្លែងចេញ-ចូលរបស់ខ្លួន ។ ការប្រើប្រាស់ប្រព័ន្ធនេះ មិនតម្រូវឱ្យមានការចំណាយណាមួយនោះទេ ។

គណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមអំពាវនាវដល់សាធារណជនទាំងអស់ចូលរួមប្រើប្រាស់ប្រព័ន្ធនេះទាំងអស់គ្នា ដើម្បីបង្ការសុខភាព ចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតសកលនេះ។

សម្រាប់ព័ត៌មានបច្ចេកទេសពាក់ព័ន្ធទៅនឹងការប្រើប្រាស់**ប្រព័ន្ធ** QR Code **"ទប់ស្កាត់កូវីដ-១៩ (Stop Covid-19)"** សាធារណជនអាចទាក់ទងទៅកាន់មជ្ឈមណ្ឌលទាក់ទងឃោសនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈ **លេខទូរសព្ទឥតគិតថ្លៃ ១២៣** (Call Center 123) ឬ ០៩៩ ៨៨៨ ៥១៦ ឬ ០១២ ៩៧៩ ០៧៩ ដែលសាធារណជនអាចហៅចូលដោយឥតគិតថ្លៃ ឬតាមរយៈគេហទំព័ររបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដែលមានអាសយដ្ឋាន www.mptc.gov.kh ឬអ៊ីម៉ែល info@mptc.gov.kh។

ថ្ងៃសៅរ៍ ៩កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**និងជាប្រធានគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**